**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

លេខៈ ៥៧៧ បទ/អ.ប.ទ

**សេចក្តីណែនាំ**

**ស្តីពី**

**ការពង្រឹង ពង្រីកបន្ថែមនូវសមត្ថភាពសេវាទូរគមនាគមន៍**

**យោង** : - លិខិតលេខ២៨ សសរ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកំណត់កាលបរិច្ឆេទនៃការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា របស់រាជរដ្ឋាភិបាលកម្ពុជា ។

- លិខិតលេខ ៥៧៧ ស.ជ.ណ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការបង្កលក្ខណៈឱ្យគណបក្សនយោ បាយ ធ្វើសកម្មភាពរបស់ខ្លួនដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃ ។

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍មានកិត្តិយសសូមជំរាបមក **លោកឧកញ៉ា លោកជំទាវ លោក អគ្គនាយក លោក លោកស្រី** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា ដើម្បីចូលរួមចំណែកអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយកាត់បន្ថយភាពក្រីក្រដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងដើម្បីចូលរួមក្នុងយុទ្ធនាការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨ ឱ្យមានសកម្មភាពខ្លាំងខ្លា និងប្រកបដោយប្រសិទ្ធភាពខ្ពស់នាថ្ងៃខាងមុខនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមធ្វើការណែនាំ **លោកឧកញ៉ា លោកជំទាវ លោកអគ្គនាយក លោក លោស្រី** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ មេត្តាជួយពង្រឹងពង្រីកបន្ថែមនូវសមត្ថភាពសេវារបស់ខ្លួនឱ្យមានគុណភាពល្អប្រសើរបំផុតទាំងក្នុង និងក្រៅប្រទេស ពិសេសត្រូវតភ្ជាប់បណ្តាញគ្នាទៅវិញទៅមកដោយគ្មានការរើសអើងជៀសវាងការកកស្ទះ ឬរអាក់រអួលដោយប្រការណាមួយក្នុងការសន្ទនា បញ្ជូន-ទទួល ព័ត៌មាន ឬ ទិន្នន័យ ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា **លោកឧកញ៉ា លោកជំទាវ លោកអគ្គនាយក លោក លោកស្រី** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ នឹងសហការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

***សូម លោកឧកញ៉ា លោកជំទាវ លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុន ផ្តល់សេវាទូរគមនាគមន៍ទាំងអស់ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។***

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨

**រដ្ឋមន្ត្រី**

**សូរ ឃុន**

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដើម្បីអនុវត្តន៍
- ឯកសារ-កាលប្បវត្តិ